ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តបន្ទាមានជ័យ
ក្រុងសិរីសោភ័ណ
រដ្ឋបាលសង្កាត់ម្កាក់

លេខ០០៤...../២២ ដ.ក

ដីកា
ស្តីពី
ការលើកទឹកចិត្តយុវជនចូលរួមក្នុងកិច្ចការសង្គម

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលស្តីពីការធ្វើវិមជ្ឈការ អំណាច តួនាទី និងការៈកិច្ចទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ ។
- យោងកិច្ចប្រជុំកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ របស់ក្រុមប្រឹក្សាសង្កាត់ម្កាក់និងយោងតាមការពិភាក្សា សម្រេចលើដីកា ស្តីពីការលើកទឹកចិត្តដល់យុវជនក្នុងការចូលរួម ក្នុងកិច្ចការសង្គមក្នុងសង្កាត់ម្កាក់ ។
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋបាលសង្កាត់ម្កាក់ ដោយយល់ឃើញថា បញ្ហាកង្វះការចូលរួមរបស់យុវជនក្នុងកិច្ចការសង្គម ជាពិសេសការចូលរួមនៅក្នុងការធ្វើ ផែនការអភិវឌ្ឍន៍ឃុំ អាចមិនឆ្លើយតបទៅ នឹង តម្រូវការរបស់យុវជននៅក្នុងសហគមន៍នៃសង្កាត់ម្កាក់ ។

ដោយមើលឃើញពីការប្រឈមរបស់យុវជនដែលពុំសូវមានឱកាសក្នុងការចូលរួមក្នុងកិច្ចការសង្គម និងដើម្បីលើកទឹកចិត្តដល់យុវជនឱ្យចូលយ៉ាងសកម្ម ក្រុមប្រឹក្សាសង្កាត់ម្កាក់

សម្រេច

ប្រការ១._ ដីកានេះមានគោលបំណង លើកកម្ពស់សិទ្ធិ និងការចូលរួមរបស់យុវជនក្នុងកិច្ចការសង្គម និងផ្តល់ឱកាសដល់យុវជនខ្មែរទាំងពីរភេទបានចូលរួមយ៉ាងសកម្មនៅក្នុងការផ្តល់យោបល់ និងលើកឡើងនូវកង្វល់នានាដែលពាក់ព័ន្ធទៅនឹងតម្រូវការរបស់យុវជនតាមគោលគំនិត និងក្តីស្រមៃរបស់ខ្លួន។

ប្រការ២._ ដីកានេះមានវិសាលភាពអនុវត្តតែនៅក្នុងដែនដី នៃសង្កាត់ម្កាក់។

ប្រការ៣._ រដ្ឋបាលសង្កាត់ផ្តល់ឱកាស និងលើកទឹកចិត្តក្រុមយុវជនចូលរួម កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាសង្កាត់។

ប្រការ៤._ រដ្ឋបាលសង្កាត់ផ្តល់ឱកាស និងលើកទឹកចិត្តឱ្យក្រុមយុវជនចូលរួមនៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់សង្កាត់ម្តាក់។

ប្រការ៥._ រដ្ឋបាលសង្កាត់នឹងស្វែងរកកិច្ចសហការ ទូលំទូលាយជាមួយអ្នកពាក់ព័ន្ធ រួមទាំងអង្គការ ជាពិសេសយុវជនដែលទទួលបានជោគជ័យ ក្នុងការចូលរួមក្នុងកិច្ចការសង្គម ឱ្យចែករំលែកបទពិសោធន៍ និងផ្តល់ការបណ្តុះបណ្តាលដល់យុវជនពីសិទ្ធិមនុស្ស ប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងសារៈសំខាននៃការចូលរួមរបស់យុវជននៅក្នុងសង្កាត់ ។

ប្រការ៦._ រដ្ឋបាលសង្កាត់ នឹង រៀបចំឱ្យមានការដាក់បង្ហាញ អំពីតារាងតម្លៃសេវារដ្ឋបាល ឱ្យបានទូលំទូលាយនៅតាមភូមិ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹង ពីតម្លៃសេវារដ្ឋបាលនៃការផ្តល់សេវារបស់របស់សង្កាត់ ប្រកបដោយតម្លាភាព។

ប្រការ៧._រដ្ឋបាលសង្កាត់ នឹង ចែករំលែកព័ត៌មានពាក់ព័ន្ធពីការចូលរួមរបស់យុវជន ក្នុងកិច្ចការសង្គម និងឱកាសសម្រាប់ការចូលរួមរបស់យុវជន ជាមួយក្រុមប្រឹក្សាសង្កាត់ ដល់ប្រជាពលរដ្ឋក្នុងសង្កាត់ ជាពិសេសសយុវជន តាមរយៈការបិទផ្សាយនៅក្តារព័ត៌មាននៅតាមភូមិ និងនៅសាលាសង្កាត់ និងទំព័រហ្វេសបុកផ្លូវការរបស់រដ្ឋបាលសង្កាត់។

ប្រការ៨._រដ្ឋបាលសង្កាត់ នឹងបង្កលក្ខណៈងាយស្រួលដល់បណ្តាញ/ក្រុមយុវជនបានជួបជុំពិភាក្សាគ្នា និងផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស ប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងតួនាទីរបស់យុវជនក្នុងការចូលរួមក្នុងកិច្ចការសង្គមដល់ប្រជាពលរដ្ឋ ជាពិសេសយុវជននៅក្នុងសហគមន៍ឱ្យបានយល់ដឹងយ៉ាងទូលំទូលាយ។

ប្រការ៩._ ក្រុមប្រឹក្សាសង្កាត់ម្តាក់ នឹងជួយសម្រួលរាល់ឯកសារដែលទាក់ទងទៅនឹងតម្រូវការរបស់យុវជនជាមួយនឹងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

ប្រការ១០._ ដីកានេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ម្តាក់, ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២

ចៅសង្កាត់

សែម ថូយ

ចំលងជូន

- រដ្ឋបាលក្រុងសិរីសោភ័ណ
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមក្រុងសិរីសោភ័ណ
  "ដើម្បីគោរពជូនជ្រាប"
- មេភូមិគ្រប់ភូមិ
  "ដើម្បីសហការអនុវត្តន៍"
- ឯកសារ-កាលប្បវត្តិ